# សុន្ទរកថា
# តំណាងអង្គការសង្គមស៊ីវិលប្រយុទ្ធនឹងជំងឺអេដស៍
# នាទិវា រំលឹកដល់ការស្លាប់ដោយសារជំងឺអេដស៍ជាតិលើកទី១២
# ២៥ ឧសភា ២០១១

សូមក្រាបថ្វាយបង្គំព្រះតេជព្រះគុណ លឹម រឿន ព្រះចៅអធិការវត្តពិកន្ទវង្សី ជាទីសក្ការៈ
សូមក្រាបថ្វាយបង្គំព្រះថេរានុថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ
សូមគោរពឯកឧត្តម លោកជំទាវ លោក លោកស្រី ជាទីគោរព
បងប្អូនអ្នកផ្ទុកមេរោគអេដស៍ អ្នកជំងឺអេដស៍ ជាទីស្នេហា។

ក្នុងនាមតំណាងឲ្យអង្គការសង្គមស៊ីវិល និងក្នុងនាមខ្ញុំព្រះករុណា ខ្ញុំបាទផ្ទាល់ ខ្ញុំមានសេចក្តីសោមនស្សរីករាយក្រៃលែង ដែលបានចូលរួមជាគណៈអធិបតីក្នុងទិវារំលឹកដល់ការស្លាប់ដោយសារជំងឺអេដស៍ជាតិលើកទី១២ និងជាលើកទី១៨សម្រាប់អន្តរជាតិ ក្រោមប្រធានបទៈ ***ប្រសិទ្ធភាពនៃការថែទាំ ដើម្បីគុណភាពនៃជីវិត***។

ការផ្តល់សេវាថែទាំ ព្យាបាលទៅអ្នកជំងឺ មានភាពល្អប្រសើរខ្លាំងណាស់ ទៅនឹងការឆ្លើយតបជាថ្នាក់ជាតិ ដែលអ្នកជំងឺអេដស៍ច្រើនជាង៩០%ទទួលបាននូវឱសថប្រឆាំងមេរោគអេដស៍ ជំងឺអេដស៍ និងការព្យាបាលដោយជំងឺឱកាសនិយម។ លទ្ធផលនេះ បានមកពីការឆ្លើយតបជាពហុវិស័យពីរាជរដ្ឋាភិបាល សង្គមស៊ីវិល ស្ថាប័នឯកជន សាសនា ដៃគូអភិវឌ្ឍន៍ និងជាពិសេសការចូលរួមដ៏ពេញលេញរបស់បងប្អូនជាអ្នកផ្ទុកមេរោគអេដស៍ ជំងឺអេដស៍ក្នុងគ្រប់ដំណាក់កាលទាំងក្នុងការកសាងផែនការ ការអនុវត្តន៍ ការតាមដាន និងវាយតម្លៃ។

ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាទីគោរព!
បងប្អូនអ្នកផ្ទុកមេរោគអេដស៍ជាទីស្រលាញ់!

ទោះបីជាមានកិច្ចខិតខំប្រឹងប្រែងប្រកបដោយផ្លែផ្កាយ៉ាងនេះក្តី ក៏អ្នកជំងឺខ្លះទទួលរងនូវផលវិបាកមួយចំនួនដូចជាៈ កង្វះខាតថ្លៃធ្វើដំណើរមកទទួលសេវា កម្រិតជីវភាពទន់ខ្សោយ មន្ទីរពេទ្យរដ្ឋមួយចំនួនតម្រូវឲ្យអ្នកជំងឺបង់ប្រាក់ពិគ្រោះជំងឺ ថ្លៃសម្រាកព្យាបាល និងធ្វើតេស្តឈាម ឱសថព្យាបាលជំងឺឱកាសនិយមប្រភេទខ្លះមិនគ្រប់គ្រាន់ ខកខានឬយឺតយ៉ាវក្នុងការធ្វើតេស្ត

ឈាមមើលអង្គបដិបប្រាណ គ្រូពេទ្យតម្រូវឲ្យអ្នកជំងឺបង់ប្រាក់ក្រៅផ្លូវការ ការទិញឈាម ការមិនយកចិត្តទុកដាក់ដល់អ្នកជំងឺ ទំនាក់ទំនងរវាងកម្មវិធីផ្នែកផ្តល់សេវាបង្ការការចម្លងពីម្តាយទៅទារក និងផ្នែកសម្ភពមិនសូវរលូន ការម៉ាក់ងាយពីសំណាក់សហគមន៍ គ្រួសារ ក្រុមគ្រូពេទ្យ និងខ្លួនឯងផ្ទាល់។

ដោយមើលឃើញនូវបញ្ហាខាងលើនេះ សង្គមស៊ីវិលសូមលើកឡើងជាសំណូមពរដូចខាងក្រោមនេះ៖

- ត្រូវបង្កើននូវគុណភាព តម្លាភាព និងភាពទទួលខុសត្រូវខ្ពស់ក្នុងការព្យាបាលដល់អ្នកជំងឺ និងត្រូវប្រាកដថាអ្នកជំងឺទាំងអស់មានភាពស្មើគ្នាក្នុងការទទួលសេវាព្យាបាលដោយមិនមានការម៉ាក់ងាយ និងការរើសអើង។
- បង្កើន និងពង្រឹងនូវការគោរពក្រមសីលធម៌វិជ្ជាជីវៈជាចំណែកមួយ ដែលគួរយកចិត្តទុកដាក់ជាទីបំផុតសម្រាប់អ្នកផ្តល់សេវា ជាពិសេសគ្រូពេទ្យក្នុងពេលបំពេញសេវា។ ការប្រើប្រាស់ពាក្យសម្តីមិនសមរម្យ និងការមិនគោរពម៉ោងការងារ ។
- មន្ទីរពេទ្យគួរតែពង្រឹងនូវយន្តការគ្រប់គ្រង ដែលរួមមាន៖ ការពង្រឹងការរៀបចំផែនការប្រចាំឆ្នាំ ផែនការធនធានមនុស្ស និងពង្រឹងគុណភាពនៃការព្យាបាលនិងសម្ភព។ សម្ភារៈបរិក្ខា ធនធានមនុស្ស និងអនាម័យជាកត្តាជម្រុញឲ្យមានការផ្តល់សេវាបានល្អ ប្រកបដោយភាពទាក់ទាញ និងមានប្រសិទ្ធភាព។ យន្តការទំនាក់ទំនងរវាងផ្នែកផ្តល់សេវាបង្ការការចម្លងពីម្តាយទៅទារក និងផ្នែកសម្ភពគួរតែត្រូវបានពង្រឹងដើម្បីបញ្ចៀសពីភាពមិនប្រក្រតីនានា។
- ក្រុមការងារថែទាំតាមផ្ទះគួរតែយកចិត្តទុកដាក់ និងទទួលខុសត្រូវខ្ពស់ក្នុងការថែទាំគាំទ្រនិងតាមដានអ្នកជំងឺ ជាពិសេសសេវាបញ្ជូនផ្សេងៗ និងជួយជំរុញនូវការពង្រឹងសេវាសុខាភិបាល។
- អង្គការនានាត្រូវបញ្ជ្រាបនូវយុទ្ធសាស្ត្រ ដើម្បីកាត់បន្ថយការម៉ាក់ងាយនិងការរើសអើងពីសហគមន៍ គ្រួសារ និងអ្នកជំងឺខ្លួនឯងផ្ទាល់។
- ត្រួតពិនិត្យមើលឡើងវិញ និងបង្កើតគោលការណ៍ និងនយោបាយផ្សេងៗ ដើម្បីផ្តល់ឱកាសឲ្យអ្នកជំងឺមានលទ្ធភាពក្នុងការមកទទួលសេវា។

ជាងនេះទៅទៀត ដោយថវិកាជាតិមានកំរិត និងការកាត់បន្ថយជំនួយពីភ្នាក់ងារអភិវឌ្ឍន៍ យើងទាំងអស់គ្នាមានកង្វល់ពីនិរន្តភាពដូចជាៈ សន្តិសុខស្បៀង ចេរភាពនៃការរស់នៅក្នុងសហគមន៍ ការកសាងសមត្ថភាព និងការផ្លាស់ប្តូរផ្នត់គំនិតរបស់អ្នកអ្នកជំងឺអេដស៍។ ពេលនេះ ឥឡូវនេះ ជាពេលវេលាសមស្រមក្នុងការពិនិត្យឡើងវិញនូវភាពខ្វះចន្លោះ ដែលកើតឡើងក្នុងការឆ្លើយតប ចំពោះអ្នកជំងឺ ដោយចេតនាក្តី ដោយអចេតនាក្តី ដើម្បីរៀបចំឲ្យមានបទអន្តរាគមន៍ដែលមានប្រសិទ្ធភាព ព្រោះវាជាការចាប់ចេញធ្វើដំណើររបស់ផែនការយុទ្ធសាស្រ្តជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបនឹងមេរោគអេដស៍ ជំងឺអេដស៍នៅកម្ពុជា។

សង្គមស៊ីវិលសូមធ្វើការប្តេជ្ញាចិត្តចូលរួមនិងថ្នាក់ជាតិ និងសហគមន៍ក្នុងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ ជំងឺអេដស៍ ប្រកបដោយផ្លែផ្កាតាមសូចនាករដែលមានចែងក្នុងផែនការយុទ្ធសាស្រ្តជាតិ គោលដៅអភិវឌ្ឍន៍សហសវត្សរ៍ និងការទទួលបានជាសកល។

ជាទីទីបញ្ចប់ខ្ញុំព្រះករុណា ខ្ញុំបាទសូមប្រគេនពរ និងគោរពជូនពរ ព្រះថេរានុថេរៈគ្រប់ព្រះអង្គ ឯកឧត្តម លោកជំទាវ លោក លោកស្រី និងអង្គពិធីទាំងមូលសូមពួបប្រទះនូវពុទ្ធពរបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូមអរព្រះគុណា!

សូមអរគុណា!